គណបក្ស សិទ្ធិមនុស្ស
HUMAN RIGHTS PARTY
បំរើ ការពារ កសាង

# កើតពីប្រជាពលរដ្ឋ របស់ប្រជាពលរដ្ឋ ដើម្បីប្រជាពលរដ្ឋ

*ព្រឹត្តិប័ត្រព័ត៌មានប្រចាំសប្តាហ៍* *ថ្ងៃសុក្រ ទី១៦ ខែមករា ឆ្នាំ២០០៩* *ព្រឹត្តិប័ត្រលេខ៦៨ ឆ្នាំទី២*


| មាតិកាព័ត៌មាន | ទំព័រ |
|---|---|
| -តុលាការកោះហៅតែ៤នាក់លើកគ្នាមកជាង២០០គ្រួសារ | ១ |
| -លោក កឹម សុខា ចុះជួបជាមួយប្រជាពលរដ្ឋនៅខេត្តកំពង់ចាម | ២ |
| -វត្តអារាមជាទីសក្ការៈបូជាក៏នៅតែទីរើសអើងផ្នែកនយោបាយ | ៣ |
| -ប្រជាពលរដ្ឋនៅខេត្តកំពង់ចាមព្រួយបារម្ភពីការស្ទះទឹកធ្វើស្រែ | ៣ |


## តុលាការកោះហៅតែ៤នាក់លើកគ្នាមកជាង២០០គ្រួសារ

តំនាងប្រជាពលរដ្ឋ ៤នាក់ស្ថិតនៅភូមិចង្រ្កង់ ស្រុកក្រចេះ ខេត្តក្រចេះ ត្រូវបានអាជ្ញាធរខេត្តកោះហៅមកសាកសួរពាក់ព័ន្ធនិងវិវាទដីធ្លីរវាងប្រជាពលរដ្ឋ នៅក្នុងភូមិចំនួនបីជាមួយនឹងក្រុមហ៊ុនដែលបានរំលោភបំពានយកដីធ្លីរបស់ពួកគាត់ប្រមាណជាង៩៩៩ha ។

នៅព្រឹកថ្ងៃព្រហស្បត្តិ៍ទី១៥នេះប្រជាពលរដ្ឋ ជាង ២០០ គ្រួសារមកពីភូមិកសាង ភូមិត្រពាំងទ្រាំង និងភូមិចង្រ្កង់ ឃុំចង្រ្កង់ បានលើកគ្នាមកឃ្លាំមើល និងតវ៉ានៅសាលាខេត្តក្រចេះ ។

បុរសវ័យប្រមាណជា ៤០ឆ្នាំ មកពីឃុំចង្រ្កង់បានរៀបរាប់ថា : ប្រជាពលរដ្ឋជាង២០០គ្រួសារបាននាំគ្នាមកតវ៉ា នៅសាលាខេត្តក្រចេះ ប៉ុន្តែត្រូវបានអាជ្ញាធរមានសមត្ថកិច្ចរារាំងក្នុងការធ្វើដំនើររបស់ពួកគាត់ ។ បុរសនោះក៏បានបន្ថែមទៀតដែរថា : គោលបំនងដែលពួកគាត់លើកគ្នាមកតវ៉ានោះ គឺដើម្បីតវ៉ាទាមទាររឿងដីដែល ក្រុមហ៊ុនឈូសឆាយយកដីស្រែចំការរបស់ប្រជាពលរដ្ឋដែលកាន់កាប់តាំងពីឆ្នាំ២០០២មកម្ល៉េះ ហើយដីប្រមាណ៩៩៩ha ដែលក្រុមហ៊ុនរំលោភយកនោះ គឺជាដីរបស់ជនជាតិព្នង ថ្វា និងជនជាតិខ្មែរដែលរស់នៅក្នុងឃុំចង្រ្កង់នោះ ។

អ្នកស្រី **រស់ ញ៉ើង** រស់នៅក្នុងភូមិត្រពាំងទ្រាំងបានបញ្ជាក់ថា : ដីរបស់គាត់ត្រូវបានក្រុមហ៊ុនរំលោភបំពានយក នៅសល់តែតិចតួច ដែលមិនអាចរស់នៅបានសំរាប់ចិញ្ចឹមកូនចៅពីព្រោះដីគេទុកឱ្យ ២០០ម ប៉ុណ្ណោះ។

លោក **អ៊ូច លេង** មន្រ្តីស៊ើបអង្កេតនៃសមាគមន៏អាដហុកការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៏នៅកម្ពុជា ដែលលោកមានវត្តមានជាមួយប្រជាពលរដ្ឋក្នុងការតវ៉ាទាមទារដីធ្លីនោះ បានឱ្យដឹងថា : អាជ្ញាធរខេត្តបានកោះអញ្ជើញតំណាងប្រជាពលរដ្ឋ ៤នាក់មកជួបជាមួយអភិបាលរងខេត្តលោក **ប្រាក់ សាវុធ** ពីព្រោះពួកគាត់ខ្លាចមានការចាប់ខ្លួនតំណាងរបស់ពួកគាត់ ទើបនាំគ្នាលើកគ្នាមកច្រើនដើម្បីការពារតំណាងរបស់ពួកគាត់ ។ លោកបានបន្តទៀតថា : ការតវ៉ារបស់អ្នកភូមិ ២០០ គ្រួសារនោះចង់ឱ្យរំលាយកិច្ចសន្យាដីដែលប្រគល់ ជាសម្បទានសេដ្ឋកិច្ចដល់ក្រុមហ៊ុនក្នុងស្រុក ។ ម្យ៉ាងទៀត គឺសុំឱ្យមានការដោះស្រាយទំនាស់ដីធ្លី និងកុំឱ្យមានការចាប់ខ្លួនតំណាងប្រជាពលរដ្ឋ ។ លោកក៏បានបន្ថែមទៀតថា : ដីដែលមានទំនាស់សព្វថ្ងៃនេះត្រូវបានអាជ្ញាធរខេត្តក្រចេះបានប្រគល់ឱ្យ ប្រជាពលរដ្ឋតាំងពីឆ្នាំ២០០២ ដែលមានលិខិតអនុញ្ញាតពីខេត្ត ឱ្យប្រជាពលរដ្ឋបង្កើតជាភូមិត្រឹមត្រូវ ហើយ

ឥឡូវបែរជាក្រុមហ៊ុនឃុំឃិត ជាមួយអាជ្ញាធរប្លន់រំលោភដីធ្លីពួកគាត់ទាំងអស់តែម្តង ។ នៅឆ្នាំ២០០៨ នោះទំហំនៃការតវ៉ារឿងដីធ្លីមានទំហំធំជាងឆ្នាំមុនៗ ចំណែកអ្នករំលោភដីធ្លីគេប្រើរូបភាពជាសម្បទានសេដ្ឋកិច្ចវិញ ។

សមាគមន៍ការពារសិទ្ធិមនុស្ស និង អភិវឌ្ឍន៍នៅកម្ពុជា ហៅថា អាដហុក បានចេញរបាយការណ៍មួយកាលពីថ្ងៃទី១២ ខែធ្នូ ទាក់ទងទៅនឹងជីទំនាស់ដីធ្លីនៅកម្ពុជា នៅក្នុងរបាយការណ៍នោះថា សកម្មភាពនៃការចោទប្រកាន់ និងចាប់ខ្លួនក្នុងរយៈពេល កន្លងមកនេះបានបង្ហាឱ្យឃើញថា ការចោទប្រកាន់ និងការចាប់ខ្លួននេះមានលក្ខណៈជាប្រព័ន្ធ ។ ប្រជាពលរដ្ឋដែលរងការចោទប្រកាន់ និងចាប់ខ្លួនពីសំណាក់តុលាការខេត្ត-ក្រុងមានចំនួន១៤៦នាក់ ក្នុងនោះមានចំនួន៥៥ នាក់កំពុងជាប់ពន្ធនាគារខេត្ត-ក្រុងយ៉ាងអយុត្តិធមិ ។ ការចោទប្រកាន់ និងចាប់ខ្លួនប្រជាពលរដ្ឋនេះជាអំពើដែលកើតចេញពីទង្វើអសមត្ថភាព នៃការដោះស្រាយដីធ្លី របស់សមត្ថកិច្ចក្នុងបំណងការពារផលប្រយោជន៍ឱ្យឈ្មួញ និងក្រុមហ៊ុនដែលក្នុងនោះមានមន្ត្រីរដ្ឋាភិបាលមួយចំនួនការពារ នៅពីក្រោយខ្នងក្នុងរឿងដីធ្លីទាំងនេះ ។

លោក **ចិន ហុងស្រី** តំណាងសាលាខេត្តក្រចេះបានគូសបញ្ជាក់ថា តាមពិតប្រជាពលរដ្ឋដែលមានដើមកំណើតរស់នៅទីនោះចំនួន៣១គ្រួសារ ប៉ុន្តែភាគច្រើនប្រជាពលរដ្ឋរស់នៅក្រៅតំបន់សម្បទានសេដ្ឋកិច្ចដែលមានគោលការហើយនោះ ។ ហើយផ្ទៃដីនោះមានទំហំ៩៩៥ha គឺរដ្ឋាភិបាលបានប្រគល់ជូនដល់ប្រជាពលរដ្ឋចំនួន៣៦៦ha និងដីសំរាប់ក្រុមហ៊ុន**ហាមុនី ជីស៊ិន** ចំនួន៦២៣ha ។ ចំណែកប្រជាពលរដ្ឋដែលអះអាងថា ពួកគាត់ជាជនជាតិព្នងហើយបានតវ៉ានោះគឺភាគច្រើនអ្នកដែលទទួលបានដីសង្គមកិច្ច ។

## លោក កឹម សុខា ចុះជួបជាមួយ ប្រជាពលរដ្ឋនៅខេត្តកំពង់ចាម

លោក **កឹម សុខា** ប្រធានគណបក្សសិទ្ធិមនុស្ស បានចុះជួបសំណេះសំណាលសួរសុខទុក្ខសកម្មជន អ្នកគាំទ្រគណបក្សសិទ្ធិមនុស្សនៅភូមិពោធិ៍ ឃុំស្វាយពោធិ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ហើយនៅរសៀលម៉ោង២នេះលោក នឹងជួបសំណេះសំណាល ជាមួយបងប្អូនប្រជាពលរដ្ឋនៅឃុំព្រែកដំបូក ស្រុកសន្ធរចំនួន ៧ឃុំទៀត ។

ប្រធានគណៈកម្មាធិការប្រតិបត្តស្រុកស្រីសន្ធរ លោក **វណ្ណ ស៊ី** បានឱ្យដឹងថាលោក **កឹម សុខា** បានជួបសំណេះសំណាលជាមួយសកម្មជនអ្នកគាំទ្រគណបក្សសិទ្ធិមនុស្ស ពីព្រោះតាំងពីក្រោយការបោះឆ្នោតរួចមក ប្រជាពលរដ្ឋរករានមិនបានជួបថ្នាក់ដឹកនាំគណបក្សសិទ្ធិមនុស្ស ។ លោកបន្តថាមូលហេតុដែលនាំលោកដើរលើមាគ៌ានយោបាយរបស់គណបក្សសិទ្ធិមនុស្ស ហើយថ្នាក់ដឹកនាំកំពូលរបស់គណបក្សសិទ្ធិមនុស្ស សុទ្ធតែមានគោលជំហរប្រជាធិបតេយ្យ ។

លោកបានឱ្យដឹងទៀតថា បើទោះបីជាគណបក្សសិទ្ធិមនុស្សបានទទួល៣អាសនៈ ឬ៤០ម៉ឺនសំឡេងក៏ដោយ ក៏ប្រជាពលរដ្ឋហាក់មានអារម្មណ៍សប្បាយចិត្តទៅវិញ ។ ប្រជាពលរដ្ឋបានយល់ច្បាស់ហើយការបោះឆ្នោតនៅថ្ងៃទី២៧ ខែកក្កដា មានអ្នកបោះឆ្នោតខ្លះឃុំស្រែករកឈ្មោះបោះឆ្នោត ការស្រែកឃុំនេះក៏មិនបានផលអ្វីដែរព្រោះគេមានផែនការរៀបចំរួចទៅហើយ ។ ក្នុងនេះប្រជាពលរដ្ឋក៏បានសំណូមពរ ឱ្យរៀបចំការបោះឆ្នោតដូចសម័យអ៊ុនតាក់ និងបោះឆ្នោតនៅទីណាក៏បានដែរ ។

សកម្មជនគណបក្សសិទ្ធិមនុស្ស មកពីឃុំស្វាយពោធរៀបរាប់ថា ប្រជាពលរដ្ឋនៅក្នុងឃុំរបស់លោកមានការអាណិតអាសូរ ដល់លោក **កឹម សុខា** ប្រធានគណបកសិទ្ធិមនុស្ស ដែលលោកខិតខំប្រឹងប្រែងដើម្បីបំរើប្រជាពលរដ្ឋ ដែលកំពុងហែលឆ្លងនូវទុក្ខវេទនាភាពក្រីក្រ ប៉ុន្តែកិច្ចខិតខំប្រឹងប្រែងរបស់លោកនៅមិនទាន់បានសំរេចនៅឡើយ ។

សកម្មជនគណបក្សសិទ្ធិមនុស្សនៅឃុំក្រាមយ៉ាម ស្រុកស្រីសន្ធរ បាននិយាយថា ការបោះឆ្នោតកន្លងទៅកាលពីថ្ងៃទី ២៧ ខែកក្កដា គណបក្សសិទ្ធិមនុស្សនៅឃុំប្រាមយ៉ាម ទទួលបាន៩០៧សំលេង ហើយសំលេងគាំទ្រនេះមិនមានការគំរាមកំហែងនិងទិញដូរនោះទេ ។ ប្រជាពលរដ្ឋនៅឃុំប្រាមយ៉ាម នៅតែពេញចិត្តកម្មវិធីនយោបាយរបស់គណបក្សសិទ្ធិមនុស្ស ដូចជាចាស់ជរាដែលមានអាយុ៦៥ឆ្នាំឡើងទៅ មានប្រាក់ឧបត្ថម្ភ ៤០០០រៀល

ក្នុងមួយខែ កូនអ្នកក្រីក្រអាចមានឱកាសរៀនសូត្រ និងសេវាសុខភាពព្យាបាលដោយមិនបង់ប្រាក់ ។

លោក **កឹម សុខា** សមាជិករដ្ឋសភារបស់គណបក្សសិទ្ធិមនុស្ស មានប្រសាសន៍ទៅកាន់សកម្មជនរបស់លោកជាផ្លូវប្រជាធិបតេយ្យគេធ្វើឱ្យប្រជាពលរដ្ឋចាក់ផុតពីភាពក្រីក្រចាកផុតពីទុក្ខវេទនា ហើយលោកបានបង្ហាញផ្លូវនេះតាំងពីលោកនៅជាប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាម្លេះ ! ប៉ុន្តែពេលនេះមិនទាន់ឃើញមានគណបក្សណាមួយធ្វើផ្លូវហ្នឹងនោះ រៀបចំផ្លូវដែលធ្វើឱ្យប្រជាពលរដ្ឋមានសិទ្ធិសេរីភាពមានប្រជាធិបតេយ្យ ជីវភាពធូរធារ ធានាសុខភាព ធានាសុវត្ថិភាពក្នុងការរស់នៅ ។

លោកគូសបញ្ជាក់ទៀតថា គណបក្សសិទ្ធិមនុស្សមិនប្រកាន់បក្សពួកអ្វីនោះទេ គឺយើងប្រមែប្រមូលអ្នកដឹកនាំមាន ស្មេរភាព ឧត្តមគតិជាតិ ហ៊ានលះបង់តស៊ូដូចជាលោក **ប៉ែន សុវណ្ណ** ជាអ្នកតស៊ូមកពីខាងកើតក៏មាន មានលោក **សឺន សូបេរ្ត៍** អ្នកតស៊ូល្អគួរជាទីទុកចិត្ត មិនក្បត់ជាតិ មិនលក់ជាតិ មិនពុករលួយ ចំណុចនេះហើយដែលធ្វើឱ្យប្រជាពលរដ្ឋគាំទ្រគណបក្សសិទ្ធិមនុស្ស ។

លោក **កឹម សុខា** អ្នកតំណាងរាស្ត្រ មណ្ឌលកំពង់ចាម មានប្រសាសន៍ថា ការបោះឆ្នោតនៅលើកនេះគឺខុសអំពីការបោះឆ្នោតលើកមុនៗ ពីព្រោះការបោះឆ្នោតលើកមុនមានការគំរាមកំហែង បាញ់សំលាប់មែន ប៉ុន្តែល្បិចលួចមានតិចជាងលើកនេះ ។ លើកនេះល្បិចលួចមានទំហំធំពោលគឺលួយលើគោកតែម្តង ។

គណបក្សសិទ្ធិមនុស្សមានពន្លកអាចទៅមុខរួចហើយ និងជាទឹកកក់ក្តៅ ដូច្នេះយើងត្រូវតែថែរក្សាវាអោយបានផល ហើយផលនោះបានទៅលើអ្នកក្រីក្រ អ្នកតូចតាច ចាស់ជរា និងកសិករ ។

## វត្តអារាមជាទីសក្ការៈបូជាក៏នៅតែទីរើសអើងផ្នែកនយោបាយ

ព្រះសង្ឃមួយអង្គ គង់នៅវត្តមួយក្នុងស្រុកបាភ្នំ ខេត្តព្រៃវែង កំពុងមានព្រះទ័យព្រួយបារម្ភខណៈពេល ព្រះចៅអធិការវត្ត លោកអាចារ្យ មេភូមិ មេឃុំ និង មន្ត្រីប៉ូលីសប៉ុស្តិ៍ គំរាមព្រះតេជគុណមិនឱ្យស្តាប់**កម្មវិធីផ្សាយសំលេងសិទ្ធិមនុស្ស** ដែលផ្សាយតាមរយៈវិទ្យុសំបុកឃ្មុំនោះទេ ។ ការបង្ខំមិនឱ្យព្រះតេជគុណស្តាប់កម្មវិធីផ្សាយសំលេងសិទ្ធិមនុស្ស គាំទ្រគណបក្សសិទ្ធិមនុស្ស ហើយប្រសិនបើព្រះតេជគុណនោះនៅតែស្តាប់ទៀត ច្បាស់ជាគេមិនអនុញ្ញាតឱ្យនិមន្តទៅឯក្រៅទេ ។

ព្រះតេជគុណដែលគង់នៅវត្តមួយក្នុងស្រុកបាភ្នំ ខេត្តព្រៃវែង មានថេរដីការថាព្រះសង្ឃ និងលោកអាចារ្យដែលគាំទ្រគណបក្សប្រជាជនកម្ពុជា បានហាមឃាត់មិនឱ្យព្រះតេជគុណស្តាប់កម្មវិធីផ្សាយរបស់គណបក្សសិទ្ធិមនុស្ស បើសិនព្រះតេជគុណនៅតែស្តាប់នោះគេមិនឱ្យព្រះតេជគុណគង់នៅក្នុងវត្ត និងមិនឱ្យនិមន្តសូត្រមន្តនៅឯក្រៅ ។

នៅពេលដែលព្រះតេជគុណនិមន្ត ទៅតាមភូមិដ្ឋានពុទ្ធបរិស័ទមួយចំនួនគាំទ្រព្រះតេជគុណ និងពុទ្ធបរិស័ទមួយចំនួនទៀតមិនគាំទ្រព្រះតេជគុណ ។

លោក **ស សែង** ប្រធានមន្ទីធម្មការ និងកិច្ចការសាសនា ខេត្តព្រៃវែងមានប្រសាសន៍ថា ការស្តាប់វិទ្យុជាផ្លូវការ មិនខុសច្បាប់នោះទេ បើគ្រាន់តែស្តាប់ព័ត៌មានកុំឱ្យតែស្តាប់ខារ៉ាអូខេ ។

លោក **វណ្ណ សូផាត** នាយករងផ្នែកទំនាក់ទំនង និងតស៊ូមតិនៃអង្គការលីកាដូបានបញ្ជាក់ថា តាមគោលការច្បាប់ការស្តាប់វិទ្យុវា គឺជាសិទ្ធិទទួលព័ត៌មាន ហើយបើមានការហាមប្រាម និងគំរាមកំហែងនោះគឺជាអំពើមួយគំរាមកំហែង សិទ្ធិទទួលព័ត៌មានប្រជាពលរដ្ឋជាពិសេសគឺព្រះសង្ឃ ។

លោក **ប៉ែន សុវណ្ណ** ប្រធានគណៈកម្មាធិការវិន័យរបស់គណបក្សសិទ្ធិមនុស្ស មានប្រសាសន៍ថានៅតាមមូលដ្ឋាន មិនត្រឹមតែព្រះសង្ឃប៉ុណ្ណោះទេ សូម្បីតែបងប្អូនប្រជាពលរដ្ឋដែលស្តាប់វិទ្យុអាស៊ីសេរី និងវិទ្យុសម្លេងសហរដ្ឋអាមេរិក ក៏អាជ្ញាធរមូលដ្ឋានមកគំរាមដែរ ។

## ប្រជាពលរដ្ឋនៅខេត្តកំពង់ចាមព្រួយបារម្ភពីការស្ទះទឹកធ្វើស្រែ

ប្រជាពលរដ្ឋប្រជាពលរដ្ឋប្រមាណ ១៥០គ្រួសារ មកពីឃុំ ៥ក្នុងស្រុកកងមាស ខេត្តកំពង់ចាម បានមកដល់តុលាការខេត្តកំពង់ចាម ដើម្បីឃ្លាំមើលខ្លាចក្រែងតុលាការចាប់ឃាត់ខ្លួនមនុស្ស៩នាក់ និងស្នើឱ្យតុលាការ ជួយអន្តរាគមន៍ដល់សហគមន៍

ដែលបានយករបាំងធ្នូសដាក់ក្នុងព្រែកអន្លង់គគី ធ្វើឱ្យស្ទះទឹកស្រក ចុះយឺតប៉ះពាល់ដល់របរធ្វើស្រែប្រាំងរបស់អ្នកភូមិ ។

លោក **ទូច សារីន** អ្នកភូមិព្រែកកុយ ឃុំព្រែកកុយ ស្រុកកងមាស់ ដែលមានឈ្មោះក្នុងដីកានោះ និងមានវត្តមាន នៅមុខតុលាការខេត្តកំពង់ចាមបានរាយការណ៍ថា ប្រជាពលរដ្ឋតវ៉ា នៅមុខតុលាការនៅថ្ងៃនេះមានគ្នាប្រហែល ១៥០នាក់ ក៏ព្រោះតែ មានសហគមន៏ខុសច្បាប់បាន បញ្ជៀសទឹកនៅក្នុងព្រែកអន្លង់គគី ធ្វើឱ្យប្រជាពលរដ្ឋធ្វើស្រែស្រូវមិនទាន់ពេលវេលា ។

ឃើញហេតុការណ៏ដូច្នេះហើយទើបនៅថ្ងៃទី២ ខែធ្នូកន្លង ទៅមានប្រជាពលរដ្ឋរាប់រយនាក់ ក៏បានទៅរុះរើរបាំងធ្នូសរបស់ សហគមន៏ខុសច្បាប់ដែលបានដាក់នៅព្រែកអន្លង់គគី ដើម្បីឱ្យទឹក ស្រកចុះលឿនសំរាប់ប្រកបរបរស្រូវប្រាំង ។ បន្ទាប់មកសហគមន៏ ខុសច្បាប់ដែលមានគ្នាប្រមាណ១០នាក់ ក៏បានដាក់ពាក្យបណ្តឹង មកតុលាការខេត្តកំពង់ចាម ។ លោកបានបន្តថា ប្រជាពលរដ្ឋបាន រុះរើរបាំងធ្នូសរបស់សហគមន៏មានគ្នារាប់រយនាក់ ចុះហេតុអ្វីបាន ជាតុលាការកោះហៅអ្នកភូមិតែ ៩នាក់ទៅវិញ ។ នៅថ្ងៃទីច័ន្ទ ទី ២២ នេះតុលាការកោះហៅអ្នកភូមិ២នាក់ទៅសាកសួរ រួមមាន ឈ្មោះ **សេង ទូច** និង **ផៃ ភិន** ។ ចំណែករូបគាត់តុលាការ សាកសួរនៅថ្ងៃទី២៤ ខែធ្នូនេះ ។

លោក **ក្រូច កែវ** ដែលមានក្នុងដីកាកោះរបស់តុលាការ ដែរនោះបានបញ្ជាក់បន្ថែមថា ប្រជាពលរដ្ឋមកពីឃុំចំនួន ៥ ដែល ទាមទារ និងឃ្លាំមើលខ្លាចក្រែងតុលាការចាប់តំណាងពួកគាត់ គឺមកពីឃុំកងតាពីង ឃុំព្រែកតាកុយ ឃុំស្ដៅ ឃុំរាយប៉ាយ ឃុំ រការ ឃុំអន្លង់គគីរ តុលាការកោះហៅរូបលោកមកសាកសួរ លោកមិនមានការភ័យខ្លាចទេ អាស្រ័យដោយរូបលោកមិនបាន ប្រព្រឹត្តខុសច្បាប់ ។

ស្រ្តីជាម្តាយរបស់លោក **ផុន ហាក់** នៅភូមិអន្លង់គគី នៅ ឃុំព្រែកកុយមានប្រសាសន៏ថា អ្នកភូមិមកច្រើនកុះករគឺគាំទ្រ ដល់អ្នកភូមិទាំង ៩នាក់ដែរតុលាការហៅសាកសួរពីព្រោះអ្នកទាំង ៩នាក់នោះមិនបានប្រព្រឹត្តខុសនោះទេ ។ គាត់មានអារម្មណ៏ភ័យ ខ្លាចពីព្រោះគាត់ គឺជាប្រជាពលរដ្ឋក្រីក្រមួយរូបគ្មានលុយកាក់ សំរាប់ឱ្យតុលាការទេ ។

យើងក៏បានសុំការបំភ្លឺពីលោក **ប្លង់ ស្នម** ប្រធានតុលាការ ខេត្តកំពង់ចាមផងដែរ ប៉ុន្តែពេលបញ្ជាក់យ៉ាងខ្លីថាជាប់រវល់ហើយ ក៏បិទទូរស័ព្ទតែម្តង ។ យោងតាមការបង្ហើបប្រាប់ពីលោក **ហេង សុវ៉ាត** មន្ត្រីសមាគមអាដហុកការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៏ នៅកម្ពុជា ប្រចាំខេត្តកំពង់ចាមបញ្ជាក់ថា នៅពេលតុលាការដាក់ លិខិតសាកសួរ ច្រើនតែឈានដល់ដីការចាប់ខ្លួន មានច្រើនរឿង ហើយដែលប្រជាពលរដ្ឋនៅខេត្តកំពង់ចាម នៅពេលពួកគាត់ទៅ តុលាការមិនដែលទៅគ្នាតិចទេ គឺទៅគ្នាច្រើនដោយបារម្ភថា នៅពេលតុលាការចាប់តំណាងពួកគាត់ៗ នឹងជួយអន្តរាគមន៏យក មកវិញ ។ ករណីនេះធ្វើឱ្យប្រជាពលរដ្ឋរៀងចាលរហូតដល់ប្រជាពលរដ្ឋ គេចវេះមិនចូលតុលាការ ។

អ្នកភូមិ៩នាក់ ដែលតុលាការកោះហៅនោះរួមមានឈ្មោះ **ទូច រឿន ក្រូច កែវ ហេង ណារិទ្ធ ផៃ ភិន ផុន ហាក់ សេក ទូច ស្នួន វណ្ណា ទូ សារិន** និង **គង់ សេរីបុត្រ** ។ អ្នកភូមិទាំង ៩នាក់ស្ថិតនៅឃុំព្រែតាកុយ ស្រុកកងមាស ។ សូមបញ្ជាក់ថា ការ លើកគ្នា មកតវ៉ានៅមុខតុលាការខេត្តកំពង់ចាមនាព្រឹកមិញនេះ ត្រូវបានតុលាការផ្អាកការសាកសួរទាំងទាន់ហាន់ ដោយរង់ចាំសាក សួរនាពេលក្រោយ ។ ចំណែកអ្នកភូមិនឹងមិនមានពេលមក តុលាការទៀតទេដោយពួកគាត់រវល់ដកស្ទូង ។


| គ្រប់គ្រងការផ្សព្វផ្សាយ | | |
|---|---|---|
| លោក | ម៉ី សាន | ទូរស័ព្ទលេខ: ០១១ ៩០៤ ០៣១ |
| កញ្ញា | គង់ វណ្ណា | ទូរស័ព្ទលេខ: ០១២ ៨៦៥ ២៥៥ |
| ផ្ទះលេខ៧២-៧៤,ផ្លូវលេខ៥៩៨, សង្កាត់បឹងកក់២,ខណ្ឌទួលគោក,ក្រុងភ្នំពេញ | | |


**ឆ្នាំ២០០៨មានករណីចាប់ឃុំខ្លួនប្រជាពលរដ្ឋយ៉ាងច្រើនពីករណីវិវាទដីធ្លី!**